# ព័ត៌មានលម្អិតសម្រាប់ធ្វើការទំនាក់ទំនង


## នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម

**អាសយដ្ឋាន:** ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**អ៊ីម៉ែល:** cambodiaip.dip@gmail.com
**គេហទំព័រ:** www.cambodiaip.gov.kh

## អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

**អាសយដ្ឋាន:** អគារលេខ៦-៨ មហាវិថីព្រះនរោត្តម (៤១) រាជធានីភ្នំពេញ
**អ៊ីម៉ែល:** info-pru@customs.gov.kh
**គេហទំព័រ:** www.customs.gov.kh.

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ក្រសួងមហាផ្ទៃ

**អាសយដ្ឋាន:** អគារលេខ ២៧៥ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
**គេហទំព័រ:** cccc.gov.kh

ARISE+
ASEAN Intellectual Property Rights

គេហទំព័រ: www.ariseplusipr.eu
អ៊ីម៉ែល: Arise+IPR@euipo.europa.eu
ហ្វេសប៊ុក: facebook.com/EUIPcooperation
ធ្វិតធ័រ: @EUIPcooperation
យូធូប: linkedin.com/company/euipcooperation/
លីងអ៊ិន: EU International Intellectual Property Cooperation

ARISE+ IPR



ខិត្តប័ណ្ណនេះត្រូវបានរៀបចំឡើងដោយ ARISE+IPR ដោយសហការជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម និងដោយមានជំនួយពី Tilleke & Gibbins ។ ខ្លឹមសារនៃខិត្តប័ណ្ណគឺជាការទទួលខុសត្រូវតែមួយគត់របស់គម្រោង ARISE+IPR និងមិនអាចនាំយកមកដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់ សហភាពអឺរ៉ុប ឬ ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (EUIPO) នោះទេ - ឧសភា ២០២១ ។


# ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា

## តើខ្ញុំគួរធ្វើយ៉ាងណានៅពេលដែលដឹងថាសិទ្ធិកម្មសិទ្ធិបញ្ញារបស់ខ្ញុំត្រូវបានគេរំលោភបំពាន?

នៅពេលដែលអ្នកដឹងពីការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នក អ្នកគួរធ្វើការស៊ើបអង្កេតមួយចំនួនដើម្បីទទួលបានព័ត៌មានអំពីការរំលោភបំពាន រួមមានភស្តុតាងបឋមអំពីការរំលោភបំពាន។ ផ្អែកលើប្រភេទ និងកម្រិត នៃការរំលោភបំពាន អ្នកអាចពិចារណាចាត់វិធានការចំពោះអ្នករំលោភបំពាន ។

## តើស្ថាប័នណាខ្លះដែលទទួលខុសត្រូវក្នុងការការពារសិទ្ធិកម្មសិទ្ធិបញ្ញានៅប្រទេសកម្ពុជា?

- នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។
- នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។
- នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។
- គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយនៃក្រសួងមហាផ្ទៃ ។
- នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ។
- អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម ។
- តុលាការ ។

## តើវិធានការនៃការអនុវត្តច្បាប់អ្វីខ្លះដើម្បីទប់ស្កាត់ ឬបញ្ឈប់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា?

ដើម្បីទប់ស្កាត់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា អ្នកគួរតែជូនដំណឹងយ៉ាងសកម្មទៅក្នុងទីផ្សារអំពីសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នក។ នេះអាចរួមបញ្ចូល ជាឧទាហរណ៍ សេចក្តីជូនដំណឹង ខិត្តប័ណ្ណ ព្រឹត្តិការណ៍បណ្តុះបណ្តាល ឬសកម្មភាពសាធារណៈផ្សេងទៀត ដែលផ្តល់ដំណឹងដល់ទីផ្សារអំពីសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នក។ ជាងនេះទៅទៀត វាជាការសំខាន់ណាស់ក្នុងស្វែងរកការការពារបន្ថែមទៀតតាមរយៈការកត់ត្រាសិទ្ធិផ្តាច់មុខនៅក្នុងប្រទេសកម្ពុជា ។

ដើម្បីបញ្ឈប់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា មានវិធានការជាច្រើន ហើយវិធានការទាំងនោះ គួរត្រូវបានរៀបចំទៅតាមប្រភេទនិងកម្រិតនៃការរំលោភបំពាន និងអ្នករំលោភបំពានដែលរងការចោទប្រកាន់។ វិធានការទាំងនោះ រួមមាន ការចេញលិខិតព្រមាន លិខិតផ្អាក និងបញ្ឈប់ វិធានការ រដ្ឋបាល ព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ។



## តើមានដំណោះស្រាយផ្លូវច្បាប់អ្វីខ្លះសម្រាប់ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញា ដែលត្រូវបានគេរំលោភបំពាន?

ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញាអាចដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងអ្នករំលោភបំពាន ដើម្បីធានាថាអ្នករំលោភបំពាន ត្រូវទទួលទោសតាមច្បាប់។ ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញាក៏អាចទាមទារសំណងការខូចខាតក្នុងនាមជាភាគីរងគ្រោះ ។ បណ្តឹងនេះ ទាំងបណ្តឹងព្រហ្មទណ្ឌនិងបណ្តឹងរដ្ឋប្បវេណី ។

អាស្រ័យលើប្រភេទ នៃការរំលោភបំពាន ម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញាអាចស្នើសុំឱ្យតុលាការចេញ វិធានការបណ្តោះអាសន្នដែលអាចបញ្ឈប់ ឬដោះស្រាយការរំលោភបំពាន ។ នេះអាច រួមទាំងដីកាបង្គាប់ឱ្យឈប់បន្តផលិតផលិតផល ឱ្យប្រគល់ទំនិញដែលបានរំលោភបំពាន ឬបំផ្លាញចោលផលិតផលដែលរំលោភបំពាន ។

## តើត្រូវមាននីតិវិធីអ្វីខ្លះដើម្បីស្នើសុំការដោះស្រាយការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា?

ទោះជានីតិវិធីជាក់លាក់ អាស្រ័យលើអាជ្ញាធរមានសមត្ថកិច្ចដែលត្រូវបានជ្រើសរើស ដើម្បីដោះស្រាយបណ្តឹងក៏ដោយ ជាទូទៅ នីតិវិធីគ្រប់ដណ្តប់លើការរៀបចំ បណ្តឹងអំពីការរំលោភបំពាន ហើយប្រសិនបើអាចកំណត់អត្តសញ្ញាណ អ្នករំលោភបំពានដែលត្រូវចោទប្រកាន់។

សម្រាប់ការដាក់ពាក្យបណ្តឹងនៅ អាជ្ញាធរមានសមត្ថកិច្ច ដូចជា ប៉ូលីស ជាអនុសាសន៍ត្រូវបញ្ចូលភស្តុតាងបឋមអំពីការរំលោភបំពានដើម្បីកម្រិតពីតម្រូវការក្នុងការស៊ើបអង្កេត។ សម្រាប់ការដាក់ពាក្យបណ្តឹងទៅតុលាការ ត្រូវបំពេញ នូវរាល់លក្ខខណ្ឌតម្រូវផ្លូវច្បាប់ទាំងអស់ នៃការដាក់ពាក្យបណ្តឹង ហើយកិច្ចការនេះអាស្រ័យលើតុលាការ និងដំណាក់កាលនៃដំណើរការនីតិវិធីរបស់តុលាការ

## តើត្រូវការភស្តុតាងអ្វីខ្លះ ដើម្បីបង្ហាញថាមានការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា?

- ភស្តុតាងពីភាពជាម្ចាស់សិទ្ធិកម្មសិទ្ធិបញ្ញា ឧទាហរណ៍ វិញ្ញាបនបត្រចុះបញ្ជី
- ភស្តុតាងអំពីការរំលោភបំពាន (កម្រិតនៃភស្តុតាងដែលតម្រូវ អាស្រ័យតាមអាជ្ញាធរមានសមត្ថកិច្ច)

## តើមានជម្រើសនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការអ្វីខ្លះ ក្រៅពីដំណោះស្រាយតាមផ្លូវតុលាការ?

នាយកដ្ឋានកម្មសិទ្ធិបញ្ញាផ្តល់សេវាដោះស្រាយវិវាទលក្ខណៈរដ្ឋបាល ដែលជាទម្រង់មួយនៃការសម្រុះសម្រួលវិវាទ។នេះជាឧបករណ៍នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធដ៏មានប្រសិទ្ធភាពនៅប្រទេសកម្ពុជា ។

ARISE+
ASEAN Intellectual Property Rights



# វិធីអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា

ខិត្តប័ណ្ណនេះគ្របដណ្តប់លើខ្លឹមសារនៃការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញាចំនួនបីប្រភេទ រួមមាន៖ ម៉ាក គំនូរឧស្សាហកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។


Funded by the European Union
EUIPO

## ម៉ាក

**តើម៉ាកជាអ្វី?**

ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយ និងសហគ្រាសមួយផ្សេងទៀត ។

**តើអ្នកអាចការពារម៉ាកនៅក្នុងប្រទេសកម្ពុជាបានដោយរបៀបណា និងម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយមានសិទ្ធិអ្វីខ្លះ?**

ម៉ាក អាចត្រូវបានការពារតាមរយៈការចុះបញ្ជីដោយផ្ទាល់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ឬតាមរយៈការប្រើប្រាស់ពីធីសារទីក្រុងម៉ាឌ្រីដ។ អ្នកដែលបានចុះបញ្ជីជាម្ចាស់ម៉ាក មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកសម្រាប់ទំនិញ ឬសេវានៃម៉ាកដែលត្រូវបានចុះបញ្ជីនោះ ។

ម៉ាក មិនត្រូវជា សញ្ញាដែលពិពណ៌នាពីទំនិញ និងសេវាដែលត្រូវបានប្រើប្រាស់ និងមិនត្រូវហាមឃាត់នៅក្នុងច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់របស់ប្រទេសកម្ពុជាទេ (ឧទាហរណ៍ ម៉ាកដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នាទៅនឹងម៉ាកល្បីៗ ឬម៉ាកផ្សេងទៀត ដែលត្រូវបានចុះបញ្ជីរួច ឬម៉ាកដែលមានសញ្ញាជាតិ ទង់ជាតិ ឬនិមិត្តរូបផ្សេងទៀត) ។

**តើអំពើអ្វីខ្លះដែលត្រូវចាត់ទុកថាជាការរំលោភបំពានលើម៉ាក?**

- ការប្រើប្រាស់ (សូមមើលខាងក្រោម) ម៉ាក ដោយតតិយជនដោយគ្មានការអនុញ្ញាត លើទំនិញ ឬសេវានៃម៉ាកដែលត្រូវបានការពារ
- ការបំពាក់ម៉ាក នៅលើទំនិញ ដោយតតិយជន ដោយគ្មានការអនុញ្ញាត

**តើអ្វីរាប់ថាជា "ការប្រើប្រាស់" ម៉ាក?**

"ការប្រើប្រាស់" ម៉ាក មានន័យថា ជាការប្រើប្រាស់ជាក់ស្តែងនូវម៉ាកដែលបានចុះបញ្ជី ចំពោះទំនិញ ឬសេវាក្នុងដំណើរការពាណិជ្ជកម្មជាធម្មតា ។ ការប្រើប្រាស់ទាំងនោះ ជាឧទាហរណ៍ រួមមាន៖

- ការប្រើប្រាស់ពាក់ព័ន្ធនឹងទំនិញ ឬសេវា ឬការផ្តល់ទំនិញ ឬសេវាសម្រាប់លក់ដែលស្ថិតក្រោមម៉ាក នេះ
- ការប្រើប្រាស់ម៉ាកក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម នៅនឹងកន្លែងអាជីវកម្ម ឬឯកសារផ្សេងៗទៀត ។

## គំនូរឧស្សាហកម្ម

**តើអ្វីទៅជាគំនូរឧស្សាហកម្ម?**

គំនូរឧស្សាហកម្ម គឺជាការផ្តុំនៃបន្ទាត់ពណ៌ ទម្រង់បីខ្នាត ឬសម្ភារណាមួយដែលរំលេចឡើងជារូបរាងពិសេសរបស់ ផលិតផល ឧស្សាហកម្ម ឬសិប្បកម្ម និងដែលអាចធ្វើជាគំរូផលិតផលឧស្សាហកម្ម ឬសិប្បកម្ម និងអាចសម្គាល់បានដោយចក្ខុ ។

**តើអ្នកអាចការពារគំនូរឧស្សាហកម្មរបស់អ្នកនៅក្នុងប្រទេសកម្ពុជាដោយរបៀបណា?**

ការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវតែដាក់ពាក្យសុំនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ។ លើសពីនេះទៅទៀត អ្នកអាចស្វែងរកការការពារគំនូរឧស្សាហកម្ម ដោយប្រើប្រព័ន្ធទីក្រុងឡាអេស្តីពីការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិ (International Hague System "IHS") នៅប្រទេសកម្ពុជា ។

**តើមានរបស់អ្វីខ្លះដែលអាច និងមិនអាចចុះបញ្ជីជាគំនូរឧស្សាហកម្មបាន?**

គំនូរដែលអាចចុះបញ្ជីបានត្រូវតែជាគំនូរថ្មី៖ ជាគំនូរដែលមិនទាន់បង្ហាញជាសាធារណៈ នៅកន្លែងណាមួយលើពិភពលោក មុនពេលដាក់ពាក្យសុំ ឬកាលបរិច្ឆេទអាទិភាពនៃការដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម។

គំនូរដែលប្រើសម្រាប់តែទទួលបានលទ្ធផលបច្ចេកទេស និងគ្មានលក្ខណៈរូបរាងពិសេស (ឧទាហរណ៍ គំនូរមុខងារ "Functional designs") មិនអាចចុះបញ្ជីបានទេ។ម្យ៉ាងវិញទៀត គំនូរទាំងឡាយណា ដែលមានលក្ខណៈផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ ក៏មិនអាចចុះបញ្ជីបានដែរ ។

**តើអំពើអ្វីខ្លះដែលត្រូវចាត់ទុកថាជាការរំលោភបំពានលើគំនូរឧស្សាហកម្ម?**

ការរំលោភបំពានលើគំនូរឧស្សាហកម្ម គឺជាការប្រើប្រាស់គំនូរដែលបានចុះបញ្ជី ដោយគ្មានការអនុញ្ញាតក្នុងការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយដែលបង្កើតឡើងដោយគំនូរ លើកលែងតែសម្ភារត្រូវបានដាក់តាំងនៅលើទីផ្សារនៅក្នុង ឬនៅក្រៅប្រទេសកម្ពុជា ដោយម្ចាស់គំនូរដែលបានចុះបញ្ជី ឬមានការព្រមយល់ព្រមពីម្ចាស់គំនូរនោះ ។





## ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ

**តើអ្វីទៅជាម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ?**

ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ (GI) សំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬរូបភាពផ្សេងៗទៀត ដែលមានលក្ខណៈញែកដាច់ ដែលជាឈ្មោះ ឬតំណាងឱ្យប្រភពដើមនៃតំបន់ភូមិសាស្រ្តមួយហើយឈ្មោះ សញ្ញាសម្គាល់និង/រូបភាពនោះសម្រាប់កំណត់អត្តសញ្ញាណទំនិញមានប្រភពក្នុងភូមិសាស្រ្តនោះដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្រ្តនោះ។

**តើមានភាពខុសគ្នាអ្វីខ្លះរវាងម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ និងម៉ាក?**

ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញខុសគ្នាពីម៉ាកត្រង់ថា ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណទំនិញដែលមានប្រភពពីកន្លែងណាមួយចំណែកឯម៉ាកត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណទំនិញឬសេវាដែលបង្កើតឡើងដោយរូបវន្តបុគ្គល ឬក្រុមហ៊ុនណាមួយ ដែលជាម្ចាស់ម៉ាក ។ ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ត្រូវបានប្រើប្រាស់ ដោយផលិតករ ឬពាណិជ្ជករទាំងអស់ ដែលផលិតផលរបស់ពួកគេ មានប្រភពមកពីទីកន្លែងណាមួយ ដែលចូលរួមចំណែកក្នុងការផ្តល់ គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈពិសេសផ្សេងទៀត ចំណែកឯ ម៉ាកអាចត្រូវបានប្រើប្រាស់ដោយម្ចាស់ម៉ាក ឬដោយមានការអនុញ្ញាតពីម្ចាស់ម៉ាក ។

ម៉ាកអាចត្រូវបានផ្ទេរកម្មសិទ្ធិ ឬផ្តល់អាជ្ញាប័ណ្ណ ចំណែកឯម៉ាកសម្គាល់ភូមិសាស្រ្តទំនិញមិនអាចត្រូវបានផ្ទេរកម្មសិទ្ធិ ឬផ្តល់អាជ្ញាប័ណ្ណបានទេ។ លើសពីនេះទៅទៀត ការការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ មានរយៈពេលមិនកំណត់ ដរាបណាការចុះបញ្ជីមិនត្រូវបានលុបចេញពីបញ្ជី ឬធ្វើមោឃភាព ដោយអនុលោមតាមច្បាប់ជាធរមាន ចំណែកឯម៉ាកតម្រូវឱ្យមានការស្នើសុំបញ្ជាក់ពីការប្រើប្រាស់ ឬមិនប្រើប្រាស់ និងចុះបញ្ជីសាជាថ្មីដើម្បីរក្សាសុពលភាព។

**អ្វីទៅបង្កើតបានជា "ការប្រើប្រាស់" ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ?**

"ការប្រើប្រាស់" ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ សំដៅដល់ការផ្តល់សម្រាប់លក់ ការផលិត ការនាំចេញ ឬនាំចូលទំនិញម៉ាកសម្គាល់ ភូមិសាស្រ្តទំនិញ។

សមាជិកនៃសមាគមន៍ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ផលិតករ និង/ឬប្រតិបត្តិករដែលអនុលោមតាមសៀវភៅបន្ទុកត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញដែលបានចុះបញ្ជី។ សិទ្ធិទាំងនេះមិន អាចផ្ទេរបានឡើយ ។

**តើនៅពេលណាដែលម៉ាកសម្គាល់ភូមិសាស្រ្តទំនិញក្លាយជាឈ្មោះទូទៅ?**

ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ មិនអាចចុះបញ្ជីឱ្យមានសុពលភាពបានទេ ប្រសិនបើវាជាពាក្យទូទៅ ពាក្យ ឬឈ្មោះ ដែលទោះបីជាវាកំណត់អត្តសញ្ញាណនៃ ទីកន្លែងនៃប្រភពទំនិញ ត្រូវបានស្គាល់ជាទូទៅដោយសាធារណជនអំពីប្រភេទជាក់លាក់នៃផលិតផលក៏ដោយ។ ថាតើពាក្យ ឬឈ្មោះ បានក្លាយជាពាក្យ ឬឈ្មោះទូទៅអាស្រ័យលើរបៀបដែលសាធារណជនប្រើប្រាស់ពាក្យនោះក្នុងពេលនោះ ។

ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញដែលទទួលបានការការពារមិនត្រូវក្លាយជាពាក្យទូទៅទេ ។

ឧទាហរណ៍ "កោះកុង" ជាឈ្មោះ នៃខេត្តមួយនៅក្នុងប្រទេសកម្ពុជាដែលមានភាពល្បីល្បាញ សម្រាប់ផលិតផលទឹកត្រីឈ្មោះ "ទឹកត្រីកោះកុង" មិនអាចត្រូវបានប្រើជាម៉ាកសម្គាល់ភូមិសាស្រ្តទំនិញសម្រាប់ទឹកត្រីនោះទេ ព្រោះថា"ទឹកត្រីកោះកុង" ដែលត្រូវគេស្គាល់ជាទូទៅថាជាឈ្មោះនៃប្រភេទទឹកត្រីជាក់លាក់មួយ។

**តើអំពើអ្វីខ្លះដែលត្រូវចាត់ទុកថាជាការរំលោភបំពានម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ?**

ការរំលោភបំពានម៉ាកសម្គាល់ភូមិសាស្រ្តទំនិញនៅក្នុងច្បាប់ រួមមាន៖

(ក) ការប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្រ្តទំនិញដែលបានចុះបញ្ជីចំពោះទំនិញដែលដូចគ្នា ឬទំនិញដែលអាចប្រៀបធៀបបានទៅនឹងទំនិញនៃម៉ាកសម្គាល់ភូមិសាស្រ្តទំនិញដែលបានចុះបញ្ជីនោះដែលការប្រើប្រាស់មិនត្រឹមត្រូវនោះទទួលបានផលប្រយោជន៍ ឬអាចទទួលបានផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ។

(ខ) ការប្រើប្រាស់ ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឱ្យនឹកគិតទៅដល់ ឬ ការបកប្រែម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ទោះបីជាប្រភពពិតប្រាកដ នៃទំនិញត្រូវបានអមដោយពាក្យ ដូចជាបញ្ជាក់ដោយពាក្យដូចជា"ស្ទីល" "យថាប្រភេទ" "ប្រភេទ" "វិធីសាស្រ្ត" "របៀប" "ត្រាប់តាម" ឬការបកប្រែពាក្យទាំងនោះ ឬពាក្យប្រហាក់ប្រហែលធ្វើឱ្យសាធរណជនភាន់ច្រឡំក៏ដោយ ។

(គ) ការក្លែងបន្លំ ឬការធ្វើឱ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតពាក់ព័ន្ធនឹងទំនិញដែលអាចនាំឱ្យមានការយល់ខុសអំពីប្រភពដើមរបស់ផលិតផល

(ឃ) ការអនុវត្តផ្សេងទៀតដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំអំពីប្រភពដើមពិតប្រាកដនៃទំនិញ ។